## កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៣៤

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបន្តកិច្ចដំណើរការនីតិវិធីសវនាការសាជាថ្មី បន្ទាប់ពីឈប់សម្រាកអស់រយៈពេលពីរសប្តាហ៍សម្រាប់ពិធីបុណ្យភ្ជុំបិណ្ឌ និងការឈប់សម្រាកបន្ថែមដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើការពិចារណាដោះស្រាយលើបញ្ហានីតិវិធីនានាដែលកំពុងជួបប្រទះ។ ដំបូងឡើយ អង្គជំនុំជម្រះ បានកំណត់កាលវិភាគដើម្បីស្តាប់សក្ខីកម្មសាក្សីអត្តលេខ 2-TCW-996 ដែលជាសាក្សីយកចេញពីការស៊ើបអង្កេតក្នុងសំណុំរឿង០០៤ ហើយជាការស្នើសុំដោយជនជាប់ចោទលោក **នួន ជា** ពាក់ព័ន្ធនឹងការដ្ឋានទំនប់អាងត្រពាំងថ្ម។ ទោះបីជាយ៉ាងនេះក្តី ក្រោយពេលនៃការចេញអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការប្រើប្រាស់ភស្តុតាងចេញពីសំណុំរឿង០០៣ និង០០៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចស្តាប់សក្ខីកម្មសាក្សីរូបនេះជាអសាធារណៈ។[1] សេចក្តីសង្ខេបនៃសក្ខីកម្មរបស់សាក្សីរូបនេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នាពេលខាងមុខ នៅពេលណាដែលប្រតិចារឹកកោសលប់នៃកិច្ចដំណើរការនីតិវិធីជាអសាធារណៈនេះ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។[2] នៅពេលរសៀលក្នុងថ្ងៃអង្គារ អង្គជំនុំជម្រះ បានចាប់ផ្តើមស្តាប់សក្ខីកម្មរបស់សាក្សីដំបូង

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "សេចក្តីណែនាំដែលត្រូវបានកែសម្រួលស្តីពីការប្រើប្រាស់កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយពីសំណុំរឿង០០៣ និង០០៤" ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥, ឯកសារលេខ E319/7/3។

[2] សាក្សីអត្តលេខ 2-TCW-996 បានផ្តល់សក្ខីកម្មនៅថ្ងៃទី២៦ និង២៧ ខែតុលា ឆ្នាំ២០១៥។ ចំពោះសារណាផ្ទាល់មាត់របស់ក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** ក្នុងការស្នើសុំសវនាការស្តាប់សក្ខីកម្មសាក្សីនេះ សូមមើល របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម លេខ៣២ អំពីសវនាការលើភស្តុតាង សប្តាហ៍ទី២៩ (ថ្ងៃទី២៨ ដល់៣០ ខែកញ្ញា ឆ្នាំ២០១៥) ទំព័រ៧។ នៅថ្ងៃទី៧ ខែតុលា មេធាវីការពារក្តីឲ្យលោក **នួន ជា** គឺលោក **វិចទ័រ កូបេ** បានធ្វើការបញ្ជាក់ពីសារៈសំខាន់នៃសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ មុននឹងសវនាការលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការកំពូល

គេក្នុងផ្នែកជំនុំជម្រះថ្មីស្តីពីការប្រព្រឹត្តមកលើជនជាតិភាគតិចវៀតណាម ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចជា៖ ការបណ្តេញចេញដោយបង្ខំ ការសម្លាប់រង្គាល ការសម្លាប់មនុស្ស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុរើសអើងពូជសាសន៍។[3] សាក្សីឈ្មោះ លោក **សៀន ស៊ង់** ជាដំបូងបានផ្តល់សក្ខីកម្មអំពីការសង្កេតឃើញរបស់គាត់ ចំពោះការសម្លាប់រង្គាលលើជនជាតិភាគតិចវៀតណាម នៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប នៅឆ្នាំ១៩៧៨។ លើសពីនេះទៅទៀត គាត់ក៏បានរម្លឹកផងដែរពីការសម្លាប់ស្ត្រីជនជាតិវៀតណាមម្នាក់នៅក្នុងកងចល័តរបស់គាត់ ដែលគាត់បាននិយាយថា ស្ត្រីម្នាក់នោះត្រូវបានសម្លាប់ និងវះយកពោះវៀន។ ដោយសារតែសាក្សីដទៃទៀតដែលត្រូវបានគ្រោងទុកសម្រាប់សប្តាហ៍នេះមិនអាចមកផ្តល់សក្ខីកម្មបាន ដូច្នេះហើយមានតែលោក **សៀន ស៊ង់** ជាសាក្សីតែម្នាក់គត់ដែលត្រូវបានស្តាប់សក្ខីកម្មជាសាធារណៈក្នុងសប្តាហ៍នេះ។ ជាការឆ្លើយតបទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តីអំពីពេលវេលាបន្ថែមដើម្បីត្រៀមរៀបចំសម្រាប់សវនាការលើបណ្តឹងសាទុក្ខនៅថ្ងៃទី១៦-១៨ ខែវិច្ឆិកា នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២វគ្គ១ អង្គជំនុំជម្រះសាលាដំបូងបានផ្អាកសវនាការលើសំណុំរឿង០០២/០២ ចាប់តាំងពីថ្ងៃពុធនេះ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា។

ក្នុងសំណុំរឿង០០២វគ្គ១។ សូមមើល របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម លេខ៣៣ អំពីសវនាការលើភស្តុតាង សប្តាហ៍ទី៣០ (ថ្ងៃទី៥ ដល់៧ ខែតុលា ឆ្នាំ២០១៥) ទំព័រ៦។ ចាប់ពីការចេញផ្សាយនូវរបាយការណ៍នេះនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥មក អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីប្រតិចារឹកកោសលប់នៃកាលបរិច្ឆេទសវនាការទាំងនោះឡើយ។

[3] ចំពោះបទចោទប្រកាន់ពាក់ព័ន្ធនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម រួមមាន៖ បទចោទប្រកាន់នៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានដូចជា ការបណ្តេញចេញ ការសម្លាប់រង្គាល ការសម្លាប់មនុស្ស និងការធ្វើទុក្ខបុកម្នេញ សូមមើលដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ វាក្យខណ្ឌ ២០៥ដល់២០៧, ២១៣ដល់២១៥, ៧៩១ដល់៨៣១។

[*] របាយការណ៍នេះ ត្រូវបានសរសេរដោយ អាឡិចសាន់ឌើ បេនហ្ស (Alexander Benz), ដា ប៉ូរ៉ាក់មុន្នី, ដានៀល ម៉ាតថេស៍ (Daniel Mattes), ខេតលីន កាហ្វប្រៀ (Caitlin McCaffrie), នំ សុថារ័ត្ន, តាយ លីណា, ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) និង ថាលីសា ហ្ស៊ឺ ហូសេន (Talisa zur Hausen) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និង យុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជាមជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University